**ព្រឹទ្ធសភា**

**អគ្គលេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៨

**សេចក្តីផ្តើម**:

នៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**:

**១.មុខងារនីតិកម្ម**:

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ១៣លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ និងនីតិកាលទី៤ ចំនួន០៨លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់<br>- បានបើកសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងរដ្ឋសភាចំនួន១១លើក ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ និងនីតិកាលទី៤ សម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៤ និងប្រជុំអន្តរគណៈកម្មការចំនួន៣៣លើក<br>- បានបង្កើតយន្តការនានា សម្រាប់នីតិកាលទី៤ (ក្រុមភូមិភាគ ក្រុមសមាជិក សមាជិកាព្រឹទ្ធសភា ក្រុមពហុភាគី ក្រុមមិត្តភាព ក្រុមជនបង្គោល ក្រុមអ្នកនាំពាក្យ គណៈកម្មការក្រមសីលធម៌ និងការពិចារណាកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន)<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ចំនួន១៤ច្បាប់ ។ | ផ្សេងៗសរុបចំនួន៤៤លើក មានអ្នកចូលរួមចំនួន ១,១១៥នាក់<br>- បានថតចម្លងឯកសារចំនួន១១,៤០៨ច្បាប់ អស់ក្រដាសចំនួន១៤០,៤៩៤សន្លឹក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៤៦លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន៤៥៧នាក់ ស្មើនឹង៣៦លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១៥ច្បាប់ពីរាជរដ្ឋាភិបាល និងចំនួន១៤ច្បាប់ ពីរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៤៤៩ច្បាប់<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន១,៥០៤ច្បាប់ ពីក្រសួង ស្ថាប័ននានា និងចាត់ចែងតាមនីតិវិធី<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន២៥ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានសភាអន្តរជាតិបានចំនួន៤២០ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំចំនួន៣៣លើក និងចុះត្រួតពិនិត្យប្រព័ន្ធសំឡេង និងកាមេរ៉ាវីដេអូចំនួន៥៩លើក |

| | |
|---|---|
| | - បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្ដីជូនដំណឹង សេចក្ដីប្រកាសព័ត៌មានចំនួន៧៩លើក។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុងនានា ចំនួន០៤លើក ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ និងសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន នៅខេត្តកំពង់ស្ពឺ កោះកុង ព្រះសីហនុ ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកណ្ដាល។ | - បានផ្ញើលិខិតបេសកកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៦០នាក់ ស្មើនឹង១៧ច្បាប់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន០៤លើក<br>- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៩៥នាក់ ស្មើនឹង ១៣លើក។ |

## ៣.មុខងារតំណាង:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខដល់ក្រុមគ្រួសារសព នាំយកបច្ច័យ ទេយ្យវត្ថុ និងគ្រឿងបរិក្ខារទៅវេរប្រគេនព្រះសង្ឃ បង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធ សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម | - រៀបចំបែបបទ ផ្ដល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្សេងៗសរុបចំនួន១,៥២៩លើក<br>- បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញអមដំណើរជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចុះស្រាវជ្រាវប្រមូលព័ត៌មាន |

និងលោកជំទាវ និងបុព្វការីជន ដែលបានពលីជីវិត ព្រមទាំងអញ្ជើញចូលរួមជាកិត្តិយសជាអធិបតី និងពិធីផ្លូវការផ្សេងៗចំនួន០១លើក នៅខេត្តព្រះសីហនុ កោះកុង កំពត តាកែវ កណ្តាល ពោធិ៍សាត់ កំពង់ចាម កំពង់ស្ពឺ រតនគិរី ស្វាយរៀង និងរាជធានីភ្នំពេញ

- ធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា ជូនដល់សាស្ត្រាចារ្យ និងនិស្សិត មកពីវិទ្យាស្ថានជាតិសង្គមកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបញ្ញាសាស្ត្រ និងសាកល-វិទ្យាល័យខេអូចំនួន១២២នាក់
- ធ្វើសិក្ខាសាលាស្តីពី ការផ្តល់ព័ត៌មានបឋមសម្រាប់សមាជិក សមាជិកាព្រឹទ្ធសភា នីតិ-កាលទី៤ អំពីតួនាទី ភារកិច្ច សមត្ថកិច្ច និងយន្តការទាំងឡាយរបស់ព្រឹទ្ធសភា
- ក្រុមសមាជិកសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានរៀបចំវេទិកាសាធារណៈចំនួន០១លើក ស្តីពី ការផ្សព្វផ្សាយសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងភាពជាតំណាងរបស់ក្រុមសមាជិកព្រឹទ្ធសភា នៅខេត្តស្វាយរៀង
- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ២២ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១០ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន២០ករណី

ពិភាក្សាការងារ ចុះតាមដានសិក្សាឈ្វេងយល់លទ្ធផលវឌ្ឍនភាពក្រោយរៀបចំវេទិកា ចុះសិក្សាឈ្វេងយល់ពីការប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជួបសំណេះសំណាលសាកសួរសុខទុក្ខ ចែកអំណោយ និងពិធីសម្ពោធស្រះទឹកចំនួន០២កន្លែង ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី សៀមរាប បន្ទាយមានជ័យ ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល កំពត តាកែវ កោះកុង ព្រះសីហនុ និងរាជធានីភ្នំពេញ

- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា បទបង្ហាញ និងពិធីចុះហត្ថលេខា ព្រមទាំងពិធីផ្សេងៗចំនួន១៥លើក
- បានរៀបចំរបាំត្រុដិ របាំជូនពរ កម្មវិធីលេងល្បែងប្រជាប្រិយ ព្រមទាំងរៀបចំពិធីសូត្រមន្ត និងពិធីជប់លៀងអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១,០៧៩នាក់ ស្មើនឹង២៨៣ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន៣៦រូប ស្មើនឹង៣៦ច្បាប់
- បានថតចម្លងឯកសារបានចំនួន៦,០៣០ច្បាប់ អស់ក្រដាសចំនួន៥៣,៨២០សន្លឹក
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១,២២៩នាក់

| | |
|---|---|
| ជំរុញការដោះស្រាយពាក្យបណ្ដឹងចំនួន ០១ករណី ទទួលពាក្យបណ្ដឹងជូនជ្រាបចំនួន ៦៧ករណី និងបានឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៦ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន៩១០លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៥១៧លើក។ | ស្មើនឹង៣២២លើក<br>- បានទទួលលិខិតចូលចំនួន៥,៧៧៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៩៦៨ច្បាប់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៦៨២លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង១៨លើក<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរពវិញ្ញាណក្ខន្ធសពចំនួន១៤លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៦នាក់<br>- បានរៀបចំអំណោយ៣០កញ្ចប់ ជូនគណៈកម្មា-ធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ និងកុមារកំព្រា<br>- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមជាសមាជិកគាំទ្របរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្ដល់អត្ថបទព័ត៌មាន និងរូបថតចំនួន ៤,១៦៤សន្លឹក ជូនអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន៨០៣នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន២២០ក្បាល និងសង |

| | |
|---|---|
| | វិញចំនួន២៥៥ក្បាល<br>- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្ដី រាជកិច្ចចំនួន១,៧៥២ក្បាល និងកាសែត ព្រះរាជក្រម ចំនួន១,០១៨ច្បាប់ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន អង្គភាព ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើតារាងស្ថិតិទិន្នន័យ និងចងក្រងសៀវភៅ បញ្ជីឈ្មោះក្រុមប្រឹក្សាឃុំ សង្កាត់ និងបេក្ខជន ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បន្ទាប់ពីបែងចែកអាសនៈដែលទំនេរ ស្របតាម មាត្រា២០ និងមាត្រា២១ថ្មី នៃច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់<br>- បានធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និង សង្កាត់ថ្មី<br>- បានបន្តផលិតសៀវភៅស្ដីពី សមិទ្ធផលព្រឹទ្ធសភា នីតិកាលទី៣ ប័ណ្ណជូនពរ សារជូនពរ និងកែ សម្រួលប្រតិទិន<br>- កំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ និង សៀវភៅបត់ស្ដីពី ព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៩<br>- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូស្ដីពី លទ្ធផល ព្រឹទ្ធសភា នីតិកាលទី៣ និង៣នីតិកាល<br>- បានផលិតទស្សនាវដ្ដីប្រចាំខែមករា ដល់មិថុនា ឆ្នាំ២០១៨ ចំនួន១៥,០០០ក្បាល<br>- បានផ្ដល់ឯកសារ សៀវភៅដែលបោះពុម្ពដោយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនដល់រដ្ឋសភា សាលាបណ្ដុះបណ្ដាលនាយទាហាននៅខេត្ត បាត់ដំបង វិទ្យាស្ថានការទូត និងទំនាក់ទំនង អន្តរជាតិ និងអនុវិទ្យាល័យព្រែកពាំងចំនួន |

| | |
|---|---|
| | ៨៨០ក្បាល<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន២៩០លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៣០៧លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន០៩លើក របស់សាស្ត្រាចារ្យ និងនិស្សិត មកពីវិទ្យាស្ថាន និងសាកលវិទ្យាល័យនានាសរុបចំនួន៥២៧នាក់ ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានអនុញ្ញាតឱ្យគណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានាចូលជួបជូនសារតាំងសម្ដែងការគួរសម និងសវនាការចំនួន២៤លើក ព្រមទាំងបានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាអញ្ជើញចូលរួមកិច្ចប្រជុំនៅក្រៅប្រទេសចំនួន០១លើក នៅសាធារណរដ្ឋសង្គមនិយមវៀតណាម<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានជួបពិភាក្សាការងារ និងសម្ដែងការគួរសម ជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន២៤លើក<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ច ចូលរួមកិច្ចប្រជុំ មហាសន្និបាត សន្និសីទ សិក្ខាសាលា វេទិកា និងពិធីផ្សេងៗចំនួន០៨លើក នៅកោះតៃវ៉ាន់ ព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋសិង្ហបុរី សាធារណរដ្ឋសង្គមនិយមវៀតណាម សហ- | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជូនសារតាំង និងជំនួបសម្ដែងការគួរសមចំនួន២៤លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន៦៣លើក<br>- បានរៀបចំសម្អាត តុបតែងសាល និងផ្ដល់សេវាភេសជ្ជៈ អាហារសម្រន់ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងកិច្ចប្រជុំចំនួន៦៧លើក ស្មើនឹង៧២៤នាក់<br>- បានថតចម្លងឯកសារចំនួន១,១៧៥ច្បាប់ អស់ក្រដាសចំនួន៧,៩៨២សន្លឹក<br>- បានផ្ដល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៤២៧នាក់ ស្មើនឹង២១៨លើក |

| | |
|---|---|
| ព័ន្ធរុស្ស៊ី ប្រទេសកាណាដា និងប្រទេសអារ៉ាប់រួមៗ | - បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ ដីកាបញ្ជូន សេចក្តីថ្លែងការណ៍ និងលិខិតឆ្លើយតបទៅក្រសួងនានា និងបណ្តាអង្គទូតនានាចំនួន៥៤លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧៧នាក់ ស្មើនឹង២៥ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៨១លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង៣២លើក<br>- ថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន០៩លើក ព្រមទាំងបានអញ្ជើញចូលរួមកិច្ចប្រជុំ និងបំពេញបេសកកម្មការងារនៅក្រៅប្រទេសចំនួន០២លើក នៅប្រទេសស្វីស និងសាធារណរដ្ឋបារាំង<br>- បានរៀបចំបែបបទជូនគណៈប្រតិភូសមាជិកព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្ម និងចូលរួមកិច្ចប្រជុំ នៅក្រៅប្រទេសចំនួន០៨លើក<br>- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សាចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាចំនួន៣០លើក<br>- បានអនុវត្តកិច្ចសហប្រតិបត្តិការជាមួយ KPI លេខាធិការដ្ឋាន APF, PIC, KAS, SES<br>- បានទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា ស្ថានទូត |

| | |
|---|---|
| | បារាំង ព្រឹទ្ធសភាបារាំង សភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល សមាគមបេសកកម្មសិក្សាអាស៊ី វិទ្យាស្ថានបារាំង សាលាភូមិន្ទរដ្ឋបាល មូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ(KAS) អង្គការសេវាកម្មអ្នកជំនាញការជាន់ខ្ពស់អាល្លឺម៉ង់ (SES), CAM, ASEAN, EDI, HEDC, IREAN, ERA, ក្រុមហ៊ុន KOHA, ក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ និងសម្រួលដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខា-សាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២,៦៣៧ច្បាប់<br>- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ចប់ការងារនីតិកាលទី៣ ព្រឹទ្ធសភា តាមការគ្រោងទុក និងការចាប់ផ្តើមដោយរលូននីតិកាលទី៤<br>- បានវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៨<br>- រៀបចំចងក្រងសម្រង់ស្ថិតិ បទបង្ហាញ របាយ-ការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែ ប្រចាំត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន២,១៦០ច្បាប់។ |

| | |
|---|---|
| | + ការងារគ្រប់គ្រងបុគ្គលិកៈ<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន២៩៣ច្បាប់<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំលេខាធិការដ្ឋានក្រមសីលធម៌ គណៈកម្មការក្រមសីលធម៌សភា ការពិចារណារៀបចំយន្តការរបស់ព្រឹទ្ធសភា នីតិកាលទី៤<br>- បានដាក់ឱ្យអនុវត្តក្រមសីលធម៌មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទីភារកិច្ច នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបញ្ចប់បទបញ្ញាផ្ទៃក្នុង ក្រមសីលធម៌សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានបោះពុម្ពសៀវភៅជាភាសាខ្មែរ បារាំង និងអង់គ្លេស ស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៨-២០២៤) ក្នុងបរិបទព្រឹទ្ធសភា នីតិកាលទី៤ (២០១៨-២០២៤) ។<br>+ ការងារបណ្តុះបណ្តាលធនធានមនុស្សៈ<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេសចំនួន៣៣វគ្គ មានសិក្ខាកាមចំនួន៤០៤នាក់ សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៦លើក មានសិក្ខាកាមចូលរួមចំនួន៤៥៤នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីរៀបចំកម្មវិធីសិក្ខាសាលាតំបន់ និងពិចារណារៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់សភាអាស៊ាន។ |

+ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានប្រជុំរៀបចំគោលការណ៍ហិរញ្ញវត្ថុ សម្រាប់នីតិកាលទី៤ និងគម្រោងថវិកាឆ្នាំ២០១៩
- បានធ្វើរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៧ និងដំណើរការអនុវត្តថវិកាឆ្នាំ២០១៨ តាមនីតិវិធី
- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែមករា ដល់ខែឧសភា ឆ្នាំ២០១៨ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែររបស់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំបែបបទប្រាក់បៀវត្ស ប្រាក់សោធននិវត្តសម្រាប់សមាជិកព្រឹទ្ធសភាថ្មី និងចាស់
- បានបញ្ចប់ការរៀបចំតម្លើងប្រាក់បំណាច់មុខងារមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានដេញថ្លៃស្តីពី ការផ្គត់ផ្គង់ការបោះពុម្ពសម្ភារៈការិយាល័យ សម្ភារៈអនាម័យ ឯកសណ្ឋាន និងប្រេងឥន្ធនៈ
- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន១៣២សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៣៣០សំណើសម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាព

| | |
|---|---|
| | ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្ដល់សេវាកេសដ្ឋៈ និងអាហារសម្រន់ ក្នុងពិធីផ្សេងៗចំនួន៩១លើក មានអ្នកចូលរួមចំនួន២,៤០៨នាក់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១,៩៣៧លើក<br>- បានថតចម្លងឯកសារចំនួន៤០,៣២៦ច្បាប់ និងចងក្រងសៀវភៅចំនួន២១១ក្បាល អស់ក្រដាសចំនួន១៨៦,៨១៨សន្លឹក និងជួសជុលសម្អាតម៉ាស៊ីនថតចម្លងចំនួន៧៦លើក<br>- បានផ្ដល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៣២៦នាក់ ស្មើនឹង២១០លើកៗ<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :<br>- រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>- បានទទួលជំនួយពីរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងបន្តបែបបទជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន លើជំនួយបរិក្ខារសម្រាប់នីតិកាលទី៤<br>- សាងសង់អគារថ្មី០១ខ្នងសម្រាប់ជាការិយាល័យធ្វើការបណ្ដោះអាសន្ន និងបញ្ចប់ការសាងសង់ឃ្លាំងថ្មី នៅខាងក្រោយអគារ E<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្ដាញទឹក និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេ |

| | |
|---|---|
| | ឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈ សារពើភ័ណ្ឌ និងបែងចែក ប្រគល់សម្ភារៈបរិក្ខារ សរុបចំនួន២,២៥៤គ្រឿង<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឱ្យមានសោភ័ណភាពល្អ<br>- រៀបចំបំពាក់អំពូលប្រើដោយថាមពលព្រះអាទិត្យ ក្នុងបរិវេណព្រឹទ្ធសភា<br>- បានតម្លើងឧបករណ៍ប្រព័ន្ធគ្រប់គ្រងទិន្នន័យ(NAS) និង Setup Driver ជូនគណៈកម្មការទាំង១០ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានតាំងពិព័រណ៍រូបភាព និងចងបដា ពាក្យស្លោក ធ្វើហ្វុងអក្សរចំនួន៥៣លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្ដៀរ និង សហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក សរុបចំនួន៣១៧លើក<br>- រៀបចំតបណ្ដាញខ្សែកាបអុបទិកសម្រាប់ Live វីដេអូ ក្នុងកិច្ចប្រជុំសំខាន់ៗពីសាលប្រជុំពេញអង្គ ទៅសាលបណ្ណាល័យ ដើម្បីបង្កលក្ខណៈងាយ ស្រួលដល់អ្នកសារព័ត៌មាន ផ្ដិតយករូបភាព និង សម្លេងបានច្បាស់<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុប ចំនួន៤៧៤គ្រឿង។ បានUpload សេចក្ដីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្ដី និងរូបភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា |

| | |
|---|---|
| | លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៧១៧ ចំណងជើង។<br>+ ការងារផ្សេងៗ :<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ៩៦២ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងកម្មវិធីផ្សេងៗចំនួន២៦២លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ដាក់លេខកូដ និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗសរុបចំនួន១,២៩៨ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB, E-Library បណ្ដាញ Facebook សរុបចំនួន៣៦,៦៥០ក្បាល។ |

II.ទិសដៅការងារឆមាសទី២ ឆ្នាំ២០១៨

សុខុដុមកម្ម ប្រក្រតីកម្ម និងការបន្តអភិវឌ្ឍស្ថាប័ន គឺជាឧត្តមភាព។

**១.មុខងារនីតិកម្ម:**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ និងវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៤។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមការបោះឆ្នោតសកល នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមរៀបចំកម្មវិធីផ្លូវការក្នុងឱកាសពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ព្រមទាំងពិធីបុណ្យជាតិផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា ALFOCOM និងវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមមហាសន្និបាត APF និង ASGPF នាខែកក្កដា នៅទីក្រុងQuebec នៃប្រទេសកាណាដា

-ការចូលរួមមហាសន្និបាត AIPA នាខែកញ្ញា នៅសាធារណរដ្ឋសិង្ហបុរី

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-ត្រៀមទៅទស្សនកិច្ចផ្លូវការក្នុងឱកាសខួប៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលនានាដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)

-ការជំរុញអនុវត្ត (MOU)សហប្រតិបត្តិការជាមួយព្រឹទ្ធសភាឥណ្ឌា និងប៉ាគីស្ថាន ដើម្បីឈានទៅបង្កើតអគ្គនាយកដ្ឋានខាងការស្រាវជ្រាវ និងអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

+ការងារគ្រប់គ្រងបុគ្គលិក:

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ។

+ការងារបណ្តុះបណ្តាលធនធានមនុស្ស:

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT)

និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ត្រៀមវាយតម្លៃបន្តកិច្ចសន្យាដល់បុគ្គលិកជាប់កិច្ចសន្យា

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀតឆ្នាំ២០១៨។

+ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

-ត្រៀមដោះស្រាយប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យបានទាន់ពេលវេលា

-ត្រៀមបោះពុម្ពដំណាច់ឆ្នាំៈ ប័ណ្ណជូនពរ ទិនានុលេខន៍ ប្រតិទិន និងប័ណ្ណរថយន្ត

-ធ្វើគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ក្នុងកម្រិតជំនាញ និងនយោបាយ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរៀបចំគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៩

-ត្រៀមរបាយការណ៍ទូទាត់ថវិកាចំណាយព្រឹទ្ធសភា ៩មាសទី១ និងប្រចាំឆ្នាំ២០១៨ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍។

+ការងារកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ ព្រមទាំងការងារផ្សេងៗ:

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារៈបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹកភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV-online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-ការងារគ្រប់គ្រងប្រព័ន្ធរក្សាទុកទិន្នន័យ (NAS)

-ចាប់ផ្តើមការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-ចាត់ចែងការចូលរួមទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា បុណ្យភ្ជុំបិណ្ឌ និងទិវាសិទ្ធិមនុស្ស១០ធ្នូ ព្រមទាំងរៀបចំ ប្រទីបសម្រាប់បុណ្យអុំទូក បណ្តែតប្រទីប និងអកអំបុក សំពះព្រះខែ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រឹងប្រែងយ៉ាងសកម្ម ដើម្បីបញ្ចប់ការងារចុងនីតិកាលទី៣ ប្រកបដោយជោគជ័យ និងបានចាប់ផ្តើមដោយរលូន នីតិកាលទី៤ ដែលតម្រូវឱ្យត្រៀមការងារពហុវិស័យជាមុនឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាពិសេស បានរៀបចំកន្លែងធ្វើការ ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន និងការបំពាក់សម្ភារៈការិយាល័យថ្មី ជូនសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៤។ រយៈពេល០៦ខែនេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពជាវិជ្ជមានក្រោយរៀបចំវេទិកាបញ្ហាប្រឈមទទួលដោះស្រាយសំណូមពរនានា សាកសួរសុខទុក្ខ និងដឹកនាំក្រុមគ្រូពេទ្យចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ មានថាមពលកាន់តែមមាញឹក ហើយមានលទ្ធផលជាផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិ និងស្ថាប័ន។ វិទ្យាស្ថានសភាកម្ពុជា(PIC) បានបើកលទ្ធភាពថ្មីដើម្បីសមាជិកសភា និងមន្ត្រីរាជការទទួលបានទស្សនៈ និងបទពិសោធន៍ថ្មីៗក្នុងការងារសភា។ តួនាទីតំបន់របស់វិទ្យាស្ថានសភាកម្ពុជា(PIC) បានលើកកម្ពស់តួនាទីតំបន់របស់សភាកម្ពុជា ដែលដៃគូអភិវឌ្ឍន៍នានា បានកោតសរសើរ និងវាយតម្លៃខ្ពស់។ ការអភិវឌ្ឍស្ថាប័ន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកាន់តែទំនើប ដើម្បីផ្សព្វផ្សាយព័ត៌មានជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងមហាជនទាំងអស់ឱ្យយល់ដឹងអំពីដំណើរការវិវត្តការងាររបស់ព្រឹទ្ធសភាបានអនុវត្តល្អ និងទូលំទូលាយជាងមុន។ ការបើកទំព័រថ្មីរបស់ព្រឹទ្ធសភាតាមជំហានថ្មី ក្នុងនីតិកាលទី៤ និងបង្កើតបាននូវឱកាស និងសក្តានុពលថ្មី ហើយការប្រឈមថ្មីៗនឹងអាចកើតឡើងផងដែរ។

ការប្តេជ្ញាធ្វើដំណើរទៅមុខជានិច្ចគឺជាឆន្ទៈរួម ក្នុងដំណាក់កាលដែលកម្ពុជាកាន់តែអភិវឌ្ឍខ្ពស់ឡើងលើគ្រប់វិស័យ។ ការបន្តពង្រឹងពង្រីកសមត្ថភាពមន្ត្រីរាជការគឺជាកាតព្វកិច្ចដែលគ្រប់អង្គភាពត្រូវចូលរួមដើម្បីបង្កើតបាននូវសេវាថ្មី គ្រប់ជ្រុងជ្រោយ ល្អ រលូន ទាន់ចិត្ត ពេញចិត្ត និងទទួលយកបានពីអតិថិជនថ្មី ក្នុងនីតិកាលទី៤នេះ។ ការបញ្ចូលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការចេះភាសាបរទេសនៅតែជាបញ្ហាធំដែលត្រូវបន្តយកចិត្តទុកដាក់ ទន្ទឹមនឹងជំនាញសំខាន់ៗពិសេសស្រាវជ្រាវ ដែលពាក់ព័ន្ធដល់ការអនុវត្តមុខងារទាំង៥។

ថ្ងៃសុក្រ ១កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨

**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ